ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**

# សាលដីកា
## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

**សភាព្រហ្មទណ្ឌ**

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៦៧

ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២

**សាលដីកា**

លេខ ២៥៦ "III"

ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២

ដោយអង្គជំនុំជម្រះដែលមានសមាសភាពដូចខាងក្រោម ៖

១-ឯកឧត្តម [redacted] ជាប្រធាន

២-ឯកឧត្តម [redacted] ជាចៅក្រម

៣-ឯកឧត្តម [redacted] ជាចៅក្រម

៤-លោកជំទាវ [redacted] ជាចៅក្រម

៥-ឯកឧត្តម [redacted] ជាចៅក្រម

**ចៅក្រមរបាយការណ៍**

ឯកឧត្តម [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] ឋានៈជាអគ្គព្រះរាជអាជ្ញារង

**ដើម្បីជំនុំជម្រះ**

-លើបណ្តឹងសាទុក្ខលេខ ១៤១ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ក្នុងការប្តឹងសាទុក្ខចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៤៧៤ "ជ" ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍បាត់ដំបង ដែលមាន៖

**បុគ្គលប្តឹងសាទុក្ខ** ៖ ឈ្មោះ [redacted] ភេទប្រុស អាយុ ៦៩ ឆ្នាំ ជនជាតិខ្មែរ មានលំនៅបច្ចុប្បន្ននៅភូមិបេង ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង។

**បុគ្គលទទួលរងដោយបណ្តឹងសាទុក្ខ ៖**

-ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី០៤ ខែកក្កដា ឆ្នាំ១៩៧២ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិរតនៈ ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង មានទីលំនៅបច្ចុប្បន្នផ្ទះលេខ១២៤ ក្រុមទី០៤ ភូមិរតនៈ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០៤ នាក់ ។ ទោសពីមុនគ្មាន។ (ក្រៅឃុំ)

-មានលោក [redacted], [redacted] ជាមេធាវីការពារ ។

**ជាប់ចោទពីបទក្លែងបន្លំឯកសារសាធារណៈ** ប្រព្រឹត្តនៅភូមិបេង ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦២៩ នៃក្រមព្រហ្មទណ្ឌ ។

**អំពីអង្គហេតុ៖**

កាលពីឆ្នាំ១៩៩៧ ឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] បានទិញដីមួយកន្លែងទំហំ ៥.០០០ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិបេង ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង ដោយមិនបានធ្វើលិខិតទិញលក់ទេ គ្រាន់តែបានប្រគល់បង្កាន់ដៃបង់ប្រាក់ និងបង្កាន់ដៃទទួលពាក្យប៉ុណ្ណោះពីឈ្មោះ [redacted] ។ លុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៨ ឈ្មោះ [redacted] បានធ្វើលិខិតផ្ទេរសិទ្ធិដីនោះដោយបន្លំស្នាមមេដៃអ្នកលក់ឈ្មោះ [redacted] ហើយបានយកលិខិតនោះទៅចុះហត្ថលេខាពីអាជ្ញាធរមានសមត្ថកិច្ច ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៦៦៨ "ង" ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តបាត់ដំបងដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ដាក់ពន្ធនាគារកំណត់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយអនុវត្តទោសព្យួរ ។

ពីបទ ក្លែងបន្លំឯកសារសាធារណៈ ប្រព្រឹត្តនៅភូមិបេង ឃុំអន្លងវិល ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៨ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ ។

២-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ១៧៥/២២ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] ក្នុងការប្តឹងឧទ្ធរណ៍ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៦៦៨ "ង" ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តបាត់ដំបង គ្រង់សេចក្តីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៤៧៤ "ជ" ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍បាត់ដំបងដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖



[redacted]

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

២-បដិសេធសាលក្រមព្រហ្មទណ្ឌលេខ ១៦៦៨ "ង" ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តបាត់ដំបងចោលជាអសារបង់ ។

៣-ឱ្យជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ៤៩ ឆ្នាំ (មានសាវតារជាតិដូចខាងលើ) រួចខ្លួនពីការចោទប្រកាន់ពីបទក្លែងបន្លំឯកសារសាធារណៈ ប្រព្រឹត្តនៅភូមិបេង ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៦២៩ នៃក្រមព្រហ្មទណ្ឌ ។

៤-សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ដោយកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី តែចាត់ទុកជាចំពោះមុខ ។

រក្សាសិទ្ធិប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញ បណ្ដឹងសាទុក្ខលេខ ១៤១ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ក្នុងការប្ដឹងសាទុក្ខ បានប្ដឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៤៣៤ "ជ" ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍បាត់ដំបង គ្រង់ចំណុចសេចក្ដីសម្រេចទាំងមូល ។

-បានឃើញ សារណាការពារ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២២ របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ។

-បានឃើញ សារណាតប ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ។

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍ឡើងធ្វើសេចក្ដីរាយការណ៍ ។

-សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលបានលើកឡើងថា ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានប្ដឹងសាទុក្ខប្រឆាំងនឹងសាលដីកាលេខ ៤៧៤ "ជ" ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍បាត់ដំបង ។ តាមបញ្ញត្តិមាត្រា ៤០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា បណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមានអានុភាពតែលើសំណងរដ្ឋប្បវេណីតែប៉ុណ្ណោះ ។ តំណាងមហាអយ្យការសុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍បាត់ដំបងទុកជាបានការ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា ខ្លួនសូមរក្សាសេចក្ដីសន្និដ្ឋានរបស់មហាអយ្យការអមតុលាការកំពូលទុកជាបានការ ។ សាលាដំបូងខេត្តបាត់ដំបងបានផ្ដន្ទាទោស ៥ ឆ្នាំ តាមមាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ ហើយកូនក្ដីខ្លួនបានប្ដឹងឧទ្ធរណ៍ គឺសាលាឧទ្ធរណ៍បាត់ដំបងសម្រេចឱ្យរួចផុតពីបទចោទប្រកាន់ ពីបទក្លែងបន្លំឯកសារសាធារណៈ ។ មួយវិញទៀតអគ្គព្រះរាជអាជ្ញាក៏មិនបានប្ដឹងសាទុក្ខនោះដែរ ។



[redacted]

សំណូមពរ សូមតម្កល់សាលដីការបស់សាលាឧទ្ធរណ៍បាត់ដំបងទុកជាបានការដដែល ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា សូមឯកភាពតាមការសន្និដ្ឋានរបស់សហភាគា ។

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា ខ្លួនសូមឯកភាពតាមការលើកឡើងរបស់មេធាវីការពារឱ្យខ្លួន ។

សំណូមពរ សូមតុលាការកំពូលតម្កល់សាលដីកាសាលាឧទ្ធរណ៍បាត់ដំបងទុកជាបានការ ។

-ក្រោយពីបានស្តាប់សេចក្តីរាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ និងចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ
## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៤១ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងក្តីនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤១៧, មាត្រា ៤១៨ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មិនបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៦៦៨ “ជ” ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តបាត់ដំបងដែលមិនបានសម្រេចពាក់ព័ន្ធនឹងសំណងរដ្ឋប្បវេណីទេ ហើយអ្នកប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមនេះមានតែជនជាប់ចោទឈ្មោះ [redacted] ប៉ុណ្ណោះ ហើយតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ៤៧៤ "ជ" ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍បាត់ដំបង បានសម្រេចឱ្យឈ្មោះ [redacted] រួចខ្លួនពីបទចោទប្រកាន់ ពីបទក្លែងបន្លំឯកសារសាធារណៈ ប្រព្រឹត្តនៅភូមិបេង ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៨ ក្នុងអង្គហេតុនៃរឿងក្តីនេះ ដូច្នេះបុគ្គលប្តឹងសាទុក្ខឈ្មោះ [redacted] ធ្លោះសិទ្ធិដោយហេតុមិនមានគុណវុឌ្ឍិជាដើមបណ្តឹងរដ្ឋប្បវេណីទេ ដូច្នេះឈ្មោះ [redacted] គ្មានសិទ្ធិក្នុងការប្តឹងសាទុក្ខប្រឆាំងនឹងសាលដីកាព្រហ្មទណ្ឌលេខ ៤៧៤ "ជ" ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍បាត់ដំបងទេ ។

## ហេតុដូច្នេះ
## សម្រេចសេចក្តី

បដិសេធបណ្តឹងសាទុក្ខលេខ ១៤១ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ របស់បុគ្គលប្តឹងសាទុក្ខឈ្មោះ ប៊ុក គាត ។



[redacted]

សាលដីកានេះបានជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ជាប្រធាន |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| លោកជំទាវ | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| លោកស្រី | [redacted] | ជាក្រឡាបញ្ជី |

**បានចម្លងត្រឹមត្រូវតាមសាលដីកាដើម។**

ថ្ងៃសុក្រ ១០ រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ថ្ងៃសុក្រ ១០ រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២

**ប្រធានអង្គជំនុំជម្រះ**

[redacted]



[redacted]